# ទិដ្ឋាការស្នាក់នៅរយៈពេលវែង
## (គោលបំណងធ្វើការងារ បណ្តុះបណ្តាល សិក្សា និងប្តីប្រពន្ធជនជាតិជប៉ុនជាដើម)

ដើម្បីស្នើសុំទិដ្ឋាការស្នាក់នៅរយៈពេលវែងគោលបំណងទៅធ្វើការងារឬស្នាក់នៅជាដើម សាមីជនត្រូវទទួលបានវិញ្ញាបនប័ត្របញ្ជាក់ពីសិទ្ធរស់នៅ (Certificate of Eligibility) ពីអ្នកធានានៅប្រទេសជប៉ុនជាមុនសិន។ សូមភ្ជាប់មកជាមួយឯកសារដូចខាងក្រោមមកកាន់ស្ថានទូតជប៉ុននៅកម្ពុជា ឬការិយាល័យកុងស៊ុលជប៉ុនប្រចាំនៅសៀមរាបដើម្បីធ្វើការស្នើសុំទិដ្ឋាការ។

*នីតិវិធីក្នុងការស្នើសុំវិញ្ញាបនប័ត្របញ្ជាក់សិទ្ធរស់នៅ សូមអោយអ្នកធានា/អញ្ជើញនៅប្រទេសជប៉ុនទាក់ទងទៅកាន់ ការិយាល័យអន្តោប្រវេសន៍ ដែលនៅជិត(ក្នុងប្រទេសជប៉ុន)។ (វិញ្ញាបនប័ត្រនេះមិនអាចស្នើសុំបាននៅក្រសួងការបរទេស ឬស្ថានទូតឡើយ)។

| | ឯកសារតម្រូវ | កំណត់ចំណាំ |
|---|---|---|
| ១ | លិខិតឆ្លងដែន ច្បាប់ដើម | · មិនមានស្នាមប្រឡាក់ ឬការខូចខាត<br>· ត្រូវមាន២ទំព័រសម្រាប់បិទទិដ្ឋាការ |
| ២ | *ពាក្យស្នើសុំទិដ្ឋាការ ច្បាប់ដើម*<br>*(បិទរូបថត១សន្លឹក)*<br><br>សេចក្តីពន្យល់អំពីការបំពេញពាក្យស្នើសុំ (ខ្មែរ) | · រូបថតបិទកាត (ថតថ្មីក្នុងរយៈពេល៦ខែ)<br>(បណ្តោយ: ៤.៥សង់ទីម៉ែត្រ x ទទឹង: ៣.៥សង់ទីម៉ែត្រ, ផ្ទៃពណ៌ស, រូបថតពណ៌ ឬសខ្មៅ)<br>· បំពេញពាក្យ "N/A" សម្រាប់សំណួរដែលមិនត្រូវនឹងលក្ខខណ្ឌរបស់អ្នក |
| ៣ | វិញ្ញាបនប័ត្របញ្ជាក់ពីសិទ្ធរស់នៅ | · មិនតម្រូវអោយដាក់ច្បាប់ដើម<br>· ច្បាប់ចម្លងអ៊ីម៉ែលប្រសិនបើស្នើសុំតាមអេឡិចត្រូនិច<br>· ច្បាប់ចម្លងជាពណ៌ ឬសខ្មៅ |

●●● ចំណាំ ●●●

(១) ប្រសិនបើចាំបាច់ត្រូវបញ្ជាក់ជាមួយក្រសួងការបរទេសជប៉ុន (នៅទីក្រុងតូក្យូ) ឬស្ថាប័នពាក់ព័ន្ធក្នុងអំឡុងពេលដំណើរការពិនិត្យ ថ្ងៃចេញលទ្ធផលអាចមួយខែក្រោយ ឬលើសនេះ។

(២) សាមីជនអាចនឹងត្រូវតម្រូវអោយដាក់ឯកសារបន្ថែម ឬមកសំភាសន៍ ក្នុងអំឡុងពេលដំណើរការពិនិត្យ។